ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២១

ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០២

សាលដីកា

លេខ : ២៣០

ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០២

ក្នុងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០២ ដោយមានសមាសភាពដូចតទៅ :-

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ស៊ុន ធឹម ជាចៅក្រម

៣- លោក ប្រាក់ គឹមសាន ជាចៅក្រម

៤- លោក ឈឹម ស៊ីផល ជាចៅក្រម

៥- លោក សោមសិរីវុឌ្ឍ ជាចៅក្រមបម្រុងការណ៍

ក្រឡាបញ្ជី

កញ្ញា សេន សុខា

តំណាងអយ្យការ

លោក ឃាង ឃារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ១៥៤ "យ" ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៧៨៦ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទ

១- លោក ឆាត់ ម៉ិន "ជាចុងបណ្តឹងសាទុក្ខ" អាយុ ៤៤ឆ្នាំ ជាតិ ខ្មែរ

២- អ្នកស្រី ម៉េង សោភា "ជាចុងបណ្តឹងសាទុក្ខ" អាយុ ៣១ ឆ្នាំ ជាតិ ខ្មែរ មុខរបរ ពាណិជ្ជករ មានទីលំនៅផ្ទះលេខ ១៦១ ផ្លូវ ចៅសេងចុង សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌ ចំការមន ក្រុង ភ្នំពេញ ។

លោក ចាន់ សុខណាង ជាមេធាវីការពារអោយដើមចោទ

និង ចុងចម្លើយ

១- អ្នកស្រី អង់ ស៊ីវឡាន "ជាម្ចាស់បណ្តឹងសាទុក្ខ" អាយុ ៤៨ ឆ្នាំ

២- លោក ប៊ូ ស៊ីម៉ុន "ជាម្ចាស់បណ្តឹងសាទុក្ខ" អាយុ ៣៨ ឆ្នាំ មានទីលំនៅផ្ទះលេខ ៤ អឺសូន្យ ផ្លូវលេខ ១៥ សង្កាត់ ផ្សារចាស់ ខណ្ឌ ដូនពេញ ក្រុងភ្នំពេញ "ផ្ទេរសិទ្ធិអោយលោក ម៉ុត តេងហ៊ែ" ។

លោក ផាត់ ពៅសំរ៉ាង ជាមេធាវីការពារអោយចុងចម្លើយ

កម្មវត្ថុបណ្តឹង : ប្តឹងសុំមោឃភាពប្លង់សំគាល់សិទ្ធិគ្មានលេខ ចុះថ្ងៃទី០២.៩.៩៦ របស់ការិយាល័យភូមិបាលខណ្ឌដង្កោ និង សុំទទួលស្គាល់សិទ្ធិកាន់កាប់ដីលេខ ភព០១៨៣៩ និង ០១៨៤០ចុះថ្ងៃទី២៧.១២.៩៩ ។

តាមបណ្តឹងសាទុក្ខលេខ ៣៨៩ ចុះថ្ងៃទី០៧ ខែ វិច្ឆិកា ឆ្នាំ ២០០១ របស់ លោក វ៉ែស្ត ឆេងវ៉ែត តំណាង ហ៊ូ ស៊ីថន និង ឈ្មោះ អង់ ស៊ីទ្យាន ប្តឹងមិនសុខចិត្តនឹងសាលដីកា លេខ ១៥៥ " យ " ចុះថ្ងៃទី១៨.១០.២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងវិនិច្ឆ័យលេខ ២១ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២៥.០១.២០០០ របស់ឈ្មោះ ផាត់ ប៊ុន ប្តឹងសុំមោឃៈភាពប្លង់សំគាល់សិទ្ធិគ្មានលេខ ចុះថ្ងៃទី ០២.៩.៩៦ របស់ការិយាល័យភូមិបាល ខណ្ឌដង្កោ សុំទទួលស្គាល់សិទ្ធិកាន់កាប់ដីលេខភព០១៨៣៩ និង ០១៨៤០ ចុះថ្ងៃទី២៧.១២.៩៩ គឺឈ្មោះអង់ស៊ីទ្យាន និង ឈ្មោះ ហ៊ូ ស៊ីថន ដោយសំអាងហេតុថា ដីនេះខ្លួន ទិញពីអ្នកលក់ដោយបានកាត់ឈ្មោះ និងធ្វើប្លង់ត្រឹមត្រូវតាមច្បាប់ ។

តាមពាក្យបណ្តឹងតប ចុះថ្ងៃទី ២៦.០១.២០០០របស់តំណាងចុងចម្លើយឈ្មោះ វ៉ែស្ត ឆេងវ៉ែត ថា ខ្លួនសុំប្តឹងមិនអោយលុបចោលបណ្ណកម្មសិទ្ធិអចលនៈវត្ថុលេខភព០១៨៤០ ចុះថ្ងៃទី២៧.១២.៩៩ និង សុំទាមទារដីទំហំ ៥៦០៧៥ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រពាំងល្វា ឃុំ កាកាប ស្រុក ដង្កោ ក្រុងភ្នំពេញ ពីឈ្មោះ ម៉េង សោភា ដោយហេតុឈ្មោះ ហ៊ូ ស៊ីថន និង ឈ្មោះ អង់ ស៊ីទ្យាន បានទិញដី ដែលស្ថិតនៅភូមិខាងលើដោយឈ្មោះ ស៊ូ គីមណាន ជាអ្នកតំការរួចហើយស៊ូ គីមណាន បានទិញដីនោះធ្វើស្រែ ក្រោយមកភាគីខាងខ្លួន ធ្វើរបងត្រូវបានឈ្មោះ ម៉េង សោភា ហាមឃាត់ ។

បានឃើញសាលក្រមវិនិច្ឆ័យលេខ ២៩ " ន " ចុះថ្ងៃទី ១២.៧.២០០០ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ២៥.០១.២០០០ របស់ដើមចោទ ឈ្មោះ ផាត់ ប៊ុន និង នាង ម៉េង សោភា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៥.០១.២០០០របស់ឈ្មោះ ផាត់ ប៊ុន និង នាង ម៉េង សោភា អោយលោកមេធាវី ទៀ ផុនគី ជាតំណាងក្នុងរឿងរបស់ខ្លួន ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៦.០១.២០០០ របស់ឈ្មោះអង់ ស៊ីទ្យាន និង ហ៊ូ ស៊ីថន អោយឈ្មោះ វ៉ែស្ត ឆេងវ៉ែត ជាតំណាងពេញសិទ្ធិរបស់ខ្លួន ទុកជាត្រឹមត្រូវតាមច្បាប់ ។

--- /--

៤_ ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ០៣.០២.២០០០ របស់ឈ្មោះស្ដែ ឆេងតែ អោយលោកមេធាវី ឈី លឹមម៉េង ធ្វើជាតំណាង និង ការពារអោយខ្លួន ទុកជាត្រឹមត្រូវតាមច្បាប់ ។

៥_ ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី ២៦.០១.២០០០របស់ឈ្មោះ ស្ដែ ឆេងតែ និង បណ្ដឹងតប របស់មេធាវី ឈី លឹមម៉េង ទុកជាត្រឹមត្រូវតាមទំរង់ តែមិនសមហេតុដោយ ផ្ទុយពីគតិច្បាប់ ។

៦_ រឹបអូសប្រាក់ប្រដាប់ក្ដីដែលឈ្មោះ ស្ដែ ឆេងតែ បានបង់ទុករួចជាស្រេច ។

៧_ ទទួលស្គាល់បណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ភព.០១៨៣៩ និង លេខ ភព.០១៨៤០ ចុះថ្ងៃទី ២៧.១២.៩៩ ទុកជាត្រឹមត្រូវតាមច្បាប់ ។ បដិសេធបណ្ណសំគាល់សិទ្ធិគ្មានលេខ ចុះថ្ងៃទី ០២.៩.៩៦ ចោលជាអសារបង់ចាប់ពីថ្ងៃនេះតទៅ ។

៨_ ទុកសិទ្ធិអោយឈ្មោះ ហ៊ូ អ៊ីមីន និង អង់ អ៊ីទ្បាន ដែលមានតំណាង ឈ្មោះ លី លឹមម៉េង ប្ដឹងទាមទារប្រាក់ថ្លៃចិញ្ចឹម ពីអ្នកលក់ដីអោយខ្លួនតាមច្បាប់ ទៅពេលក្រោយទៀត ។

៩_ អោយឈ្មោះ ហ៊ូ អ៊ីមីន និង អង់ អ៊ីទ្បាន បង់ប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី និង ពន្ធតែង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល រង្វាន់សាក្សី៣០០០រៀល រង្វាន់អ្នកប្រគល់ដីកា កោះ ២០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០រៀល ដែលតំណាង ដើមចោទ បានបង់រួចហើយ ។

កាលបើផុតកំណត់ប្ដឹងឧទ្ធរណ៍បង្គាប់អោយឈ្មោះ ហ៊ូ អ៊ីមីន និង អង់ អ៊ីទ្បាន សង ប្រាក់ ៧០០០រៀលទៅអោយដើមចោទវិញ និង អោយបង់ពន្ធសមាមាត្រ ១ភាគរយ លើតំលៃ ដីផ្ទៃទំហំ ៥៦៤១៤ម៉ែត្រការ៉េ គិតជាទឹកប្រាក់សរុប ២៨២.០៧០ដុល្លារអាមេរិក គឺត្រូវជា ២៨២០,៧០ដុល្លារអាមេរិក ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ៨០ភាគរយ និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

១០_ សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខតំណាងគូភាគី បើកផ្លូវឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ២៥៩ ចុះថ្ងៃទី២៤.០៨.២០០០របស់ឈ្មោះ ស្ដែឆេងតែ ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ២៩ "ន" ចុះថ្ងៃទី ១២.៧.២០០០របស់តុលាការក្រុងភ្នំពេញ លើសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៦៦ "ឃ" ចុះថ្ងៃទី ២៦.០៤.២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :_

១_ ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៤.០៨.២០០០ របស់ឈ្មោះ ស្ដែ ឆេងតែ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែមិនសមហេតុដោយខុសនឹងគតិច្បាប់ ។

២. តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ២៨ " ន " ចុះថ្ងៃទី ១២.៧.២០០០ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣. កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់ទុករួចហើយ គិតជូនចុះបញ្ជីក្តី និង ពន្ធតែម ចំនួន ២៥៥០រៀល ដង្វាន់ក្រឡាបញ្ជីការពិបប្រាក់ចំនួន ៤៥០រៀល ចំណាយប្រគល់លើដីកាកោះចំនួន៥០០០រៀល និង អាករតុលាការ ចំនួន ៥០០០រៀល ។

៤. សាលដីកានេះជាស្ថាពរ និង ប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងដើមចោទ និង មេធាវីការពារចុងចម្លើយ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ១៦ ចុះថ្ងៃទី ១០.០៥.២០០១ របស់រ៉ែស្ត រេងរ័ត ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦៦ " ឃ " ចុះថ្ងៃទី ២៦.០៤.២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចកំបាំងមុខ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៥៥ " ឃ " ចុះថ្ងៃទី ១៨.១០.២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១. ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី ១០.០៥.២០០១ របស់ឈ្មោះរ៉ែស្ត រេងរ័ត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២. តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ ៦៦ " ឃ " ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ទុកនៅបានការដដែល ។

៣. សាលដីកានេះជាស្ថាពរនិងប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងដើមចោទកំបាំងមុខចុងចម្លើយដែលទាស់ទុកជាចំពោះមុខៗបើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៨៨ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០១របស់លោក រ៉ែស្ត រេងរ័ត តំណាងឲ្យ ស៊ីមីន និង ឈ្មោះ អង់ អ៊ីវ្យាន ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ១៥៥ " ឃ " ចុះថ្ងៃទី ១៨.១០.២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចកំបាំងមុខ ។

បានឃើញសារណា ចុះថ្ងៃទី ២៤.៦.២០០២របស់រ៉ែស្ត រេងរ័ត ។

បានឃើញសារណាតប ចុះថ្ងៃទី ០១.៧.២០០២ របស់ផាត់ ម៉ុត និង មេងសោភា

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា: សាលដីការបស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

--- ---

បានស្តាប់អំណានសារណារបស់លោក វ៉ែស្ត ឆេងរ៉ែត ជាចុងចម្លើយ និង ជាម្ចាស់បណ្តឹងសាទុក្ខ ។

បានស្តាប់អំណានសារណាតបរបស់លោក ផាត់ ប៊ុន និង អ្នកស្រីមៀង សោភា ជាចុងចម្លើយ និង ជាចុងបណ្តឹងសាទុក្ខ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ចាន់ សុខហាង ជាមេធាវីការពារអោយដើមចោទ នាពេលសវនាការបានលើកឡើងថា: ដីពីរឡូត៍ដែលមានទំហំ៣២១៩១ម៉ែត្រការ៉េ និង ទំហំ ២៤២២៣ម៉ែត្រការ៉េ សរុបទំហំ៥៦៤១៤ ស្ថិតនៅសង្កាត់កាកាប ខណ្ឌដង្កោ កូនក្តីខ្លួន បានទិញពីលោក តៅ ចន្ថា តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដីរវាងលោកតៅចន្ថា និង កូនក្តីខ្លួន ចុះថ្ងៃទី ០៩.១២.៩៩ និង ចុះថ្ងៃទី ០៩.១២.៩៩ រវាងលោកតៅ ចន្ថា និង កូនក្តីខ្លួន និងអ្នកស្រី មៀង សោភា ។ ក្រោយពីធ្វើការផ្ទេរសិទ្ធិរួចមកកូនក្តីខ្លួន បានទៅបំពេញបែបបទស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី ។

តាមពាក្យបណ្តឹងពីប្រជាពលរដ្ឋ និង តំណាងប្រជាពលរដ្ឋ ចុះថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ ១៩៩៧ ដែលបានលក់ដីអោយលោក ហ៊ូ អ៊ីម៉ុន និង អង់ អ៊ុំច្បារ ពីថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៦បានឡើងសុំនិរាករណ៍លើកិច្ចសន្យាទិញ លក់ ដោយហេតុថា ភាគីអ្នកទិញ គ្រាន់តែបានប្រគល់ប្រាក់កក់ ហើយមានរយៈពេល ៩ខែមកហើយ មិនបានប្រគល់ប្រាក់តាមកិច្ចសន្យា ។ យោងតាមមាត្រា ៣៤ នៃក្រឹត្យច្បាប់លេខ ៣៨ក្រម អ្នកលក់ និង អ្នកទិញត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនអោយបានត្រឹមត្រូវ ។

ដូច្នេះពិនិត្យលើសាលក្រម និង សាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាសំរេចតម្កល់សាលដីកាលេខ១៥៥ "យ" ចុះថ្ងៃទី ១៨.១០.២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណាការពាររបស់តំណាងចុងចម្លើយ សារណាឆ្លើយតបរបស់ដើមចោទ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៨៩ ចុះថ្ងៃទី០៧.១១.២០០១របស់ឈ្មោះ វ៉ែស្ត ឆេងរ៉ែត តំណាងអោយអ្នកស្រី អង់ អ៊ុំច្បារ និង លោក ហ៊ូ អ៊ីម៉ុន ដើម្បីឡើង

ក្នុងអំណាចច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជម្រះបានដោយយោងតាមមាត្រា១៥ នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្ដី ។

- យល់ឃើញថា ភាគីទាំងពីរ សុទ្ធតែបានប្ដឹងសុំមោឃភាពបណ្ណសំគាល់សិទ្ធិកាន់កាប់ដីក្រោមទំ ៥២០៧៥ម៉ែត្រការ៉េរបស់គ្នាទៅវិញទៅមក និង ទាមទារដីទំនាស់នេះធ្វើជាកម្មសិទ្ធិរៀងខ្លួន ។

- យល់ឃើញថា បណ្ណសំគាល់សិទ្ធិគ្មានលេខ ចុះថ្ងៃទី ០២.៩.៩៦ របស់អ្នកស្រី អង់ ស៊ីម្យ៉ាន និង លោក ហ៊ូ ស៊ីម៉ុន គ្មានសុពលភាពគតិយុត្តទៀតហើយ ព្រោះថា:-

- ដីទំ៥២០៧៥ម៉ែត្រការ៉េនេះ នៅឡើយជារបស់ប្រជាជន១៦គ្រួសារ បានយល់ព្រមលក់ដីនេះទៅអោយឈ្មោះ ហ៊ូ ស៊ីម៉ុន និង អង់ ស៊ីម្យ៉ាន តាមរយៈឈ្មោះសី ឈាំ និង ស៊ី ហឿន ដោយមានកិច្ចសន្យាលក់ ទិញ ចុះថ្ងៃទី ១២.៨.៩៦ ព្រមទាំងមានកក់ប្រាក់មួយចំនួន ។ ប៉ុន្តែបែរជាឈ្មោះ ហ៊ុម ញ៉ៅ ដែលគ្រាន់តែជាសាក្សីក្នុងកិច្ចសន្យាទិញ លក់នេះជាអ្នកទទួលប្រាក់បង្គ្រប់ ហើយឈ្មោះ សូ សំណាន ជាអ្នកស្នើសិទ្ធិកាន់កាប់ដីទៅវិញ "លិខិតស្នើសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី ១៨.៨.៩៦" ។

- ប្រាំមួយខែក្រោយមក គឺនៅថ្ងៃទី ៣០.៥.៩៧ តំណាងប្រជាជនទាំង ១៦គ្រួសារ បានដាក់ពាក្យបណ្ដឹងទៅលោកអភិបាលខណ្ឌ ដង្កោ សុំមោឃភាពកិច្ចសន្យាលក់ ទិញដី ចុះថ្ងៃទី១២.៨.៩៦ ដោយលើកយកមូលហេតុថា អ្នកទិញមិនបំពេញកាតព្វកិច្ចរបស់ខ្លួន គឺមិនបានប្រគល់លុយបន្ថែមលើប្រាក់កក់អោយគ្រប់ចំនួនតាមកិច្ចសន្យា ។

- តាមលិខិតលេខ ១២២មន ចុះថ្ងៃទី០២.៦.៩៧ លោកអភិបាលខណ្ឌ ដង្កោ បានចេញលិខិតបដិសេធមិនទទួលស្គាល់ហត្ថលេខារបស់លោក មាស សំអាង ចៅសង្កាត់កាកាប លើលិខិតស្នើសិទ្ធិកាន់កាប់ដីពីឈ្មោះ សូ សំណាន មកឈ្មោះ អង់ ស៊ីម្យ៉ាន និង ហ៊ូ ស៊ីម៉ុន និង លើបណ្ណសំគាល់សិទ្ធិកាន់កាប់ដីគ្មានលេខ របស់អង់ ស៊ីម្យ៉ាន និង ហ៊ូ ស៊ីម៉ុន ។ ដោយមូលហេតុអ្នកទិញ មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យាទិញលក់ គឺមិនទាន់បានប្រគល់ប្រាក់ថ្លៃទិញដីអោយគ្រប់ចំនួនទៅអ្នកលក់ ឯអ្នកលក់ ក៏មិនទាន់បានប្រគល់បង្កាន់ដៃទទួលពាក្យសុំកាន់កាប់ដីអោយអ្នកទិញទៅទៀត ។ លិខិតបដិសេធនេះបានចម្លងជូនសាលាក្រុងភ្នំពេញ សាលាសង្កាត់កាកាប និង គ្រប់ការិយាល័យទាំងអស់ក្នុងខណ្ឌ ដង្កោ ។

- បណ្ណសំគាល់សិទ្ធិកាន់កាប់ដីរបស់អ្នកស្រី អង់ ស៊ីម្យ៉ាន និង លោកហ៊ូ ស៊ីម៉ុន គ្មានលេខ គ្មានហត្ថលេខារបស់អភិបាលខណ្ឌ គ្មានការយល់ព្រមពីអភិបាលក្រុងភ្នំពេញ កាលបរិច្ឆេទនៃកំណត់ហេតុអង្កេតវាស់វែងដី និង ចេញបណ្ណសំគាល់សិទ្ធិគ្មានលេខនេះ គឺថ្ងៃទី០២.៩.៩៦ដូចគ្នា ដែលជាការខុសទៅនឹងនីតិវិធី ។

- តាមលិខិតលេខ ០០០៥របក ចុះថ្ងៃទី ១៨.០១.២០០០ប្រធានការិយាល័យភូមិបាលខណ្ឌ ដង្កោ បានបដិសេធមិនទទួលស្គាល់បណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីរបស់ហ៊ូ ស៊ីម៉ុន និង អង់ ស៊ីម្យ៉ាន ដោយមូលហេតុបណ្ណទាំងពីរនេះពុំត្រឹមត្រូវតាមគោលការណ៍ច្បាប់ ។

- យល់ឃើញថា បណ្ណសំគាល់សិទ្ធកាន់កាប់អចលនវត្ថុលេខក០១៨៣៨ ចុះថ្ងៃទី២៧.១២.៩៨ របស់ឈ្មោះ ផាត់ ប៊ុន និង បណ្ណសំគាល់សិទ្ធលេខក ០១៨៤០ ចុះថ្ងៃទី២៧.១២.៩៨របស់ឈ្មោះ ម៉េង សោភា គឺជាបណ្ណត្រឹមត្រូវតាមច្បាប់ពីព្រោះថាៈ-

- ប្រជាជនចំនួន ១៦គ្រួសារ ក្រោយពីបានបង្កបង្កើនផលកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី ១២.៨.៩៦ ហើយ គឺនៅលើលិខិតផ្ទេរសិទ្ធកាន់កាប់ដី ចុះថ្ងៃទី ១២.៧.៩៨ ទៅឲ្យឈ្មោះ គីម ញាំ "ដែលជាអ្នកតំណាង" ដើម្បីកាន់កាប់បន្តតែដោយរាងខាងឈ្មោះអ្នកផ្ទេរ ប្រគល់ប្រាក់ឲ្យគ្រប់ចំនួនដូចលើកមុនទៀតប្រជាជនក៏សរសេរក្នុងលិខិតផ្ទេរសិទ្ធនេះថាមិនឲ្យគីម ញាំ ទទួលប្រាក់ថ្លៃដីពីពៅ ចន្ថា "តំណាងឲ្យឈ្មោះ ផាត់ ប៊ុន និងម៉េងសោភា" ទេ ។ នៅថ្ងៃទី ១២.៧.៩៨ ដដែលប្រជាជនចំនួន ១៦គ្រួសារ បានធ្វើលិខិតផ្ទេរទៀតទទួលប្រាក់ថ្លៃដីពី ពៅ ចន្ថា ផ្ទាល់ព្រមទាំងបានប្រគល់បង្កាន់ដៃទទួលពាក្យសុំកាន់កាប់ដីមកឲ្យពៅ ចន្ថា ផងដែរ ។

- នៅថ្ងៃទី ០៩.១២.៩៨ ឈ្មោះ ពៅ ចន្ថា បានធ្វើលិខិតផ្ទេរសិទ្ធកាន់កាប់ដីទាំងនេះមកឲ្យឈ្មោះ ផាត់ ប៊ុន និង ម៉េង សោភា ដោយមានការបញ្ជាក់ពីចៅសង្កាត់ កាកាប និង អភិបាលខណ្ឌ ត្រឹមត្រូវ ហើយឈ្មោះ ផាត់ ប៊ុន និង ម៉េង សោភា ក៏ដាក់ពាក្យស្នើសុំកាន់កាប់ដីធ្លី ។ សាលាខណ្ឌ ដង្កោ ក៏បានបិទប្រកាសជូនដំណឹងដល់សាធារណជន ពីថ្ងៃទី ១០.១២.៩៨ ដល់ថ្ងៃទី ២១.១២.៩៨ តែពុំមានជនណាមកប្តឹងតវ៉ាទេឡើយ ។

- នៅថ្ងៃទី ២៧.១២.៩៨ ប្រធាននាយកដ្ឋានសុរិយោដីរាជធានីភ្នំពេញ បានចេញបណ្ណសំគាល់សិទ្ធកាន់កាប់អចលនវត្ថុលេខ ន.ឋ.០០៦៤ក០១៨៣៨ឲ្យឈ្មោះ ផាត់ ប៊ុន និង បណ្ណលេខ ន.ឋ.០០៦៥ក០១៨៤០ឲ្យឈ្មោះ ម៉េង សោភា យោងតាមកំណត់ហេតុអង្កេត ចុះថ្ងៃទី ២៤.១២.៩៨ ។

- នៅថ្ងៃទី ១៦.៦.២០០០ មន្ទីរសុរិយោដីក្រុងភ្នំពេញ បានបញ្ជាក់តាមលិខិតលេខ ១៦៩១មនស.សុភ ថាៈ បណ្ណសំគាល់សិទ្ធដែលមានលេខក០១៨៣៨ និងលេខក០១៨៤០ ពិតជាត្រឹមត្រូវបានចុះបញ្ជីការត្រឹមត្រូវជាមួយឯកសារដែលបានតម្កល់ទុក ហើយបណ្ណនេះពុំមានការកាត់ពន្ធដល់ការបញ្ចាំ ជួល លក់ដូរ ធ្វើអំណោយឲ្យជនណាទៀតឡើយ ។

- យល់ឃើញថា ឈ្មោះ ម៉ែន ឆេងរ៉េត ដែលអះអាងថាឈ្មោះ អង់ ស៊ុយវ៉ាន និង ហ៊ូ អ៊ីម៉ុន បានទិញដីពីឈ្មោះ លី ម៉ង់ និង ឆឹ ឡេង នោះគ្មានភស្តុតាងអ្វីក្រៅពីកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី ១២.៨.៩៦ និង បណ្ណសំគាល់សិទ្ធគ្មានលេខ ដែលត្រូវបានប្រជាជនជាម្ចាស់ដី និង អាជ្ញាធរ មានសមត្ថកិច្ចមិនសហស់រួចទៅហើយនោះទេ ។

- យល់ឃើញថា ការដែលឈ្មោះ វ៉ែត វេងវ៉ែត អង់ អ៊ីមប្រាន និង ញ៉ូ អ៊ីម៉ុន ពុំបានថ្លែងតវ៉ានៅពេលដែលអាជ្ញាធរ មិនប្រកាសជូនដំណឹងអំពីពាក្យសុំកាន់កាប់ដីរបស់ឈ្មោះ ផាត់ ប៊ុន និង ទេង សោភា នោះបញ្ជាក់អោយឃើញថា អ្នកទាំងពីរនាក់នេះពុំដែលបានកាន់កាប់ដីទំនាស់ដូចដែលខ្លួន បានអះអាងទេ ដូច្នេះមិនអាចក្លាយទៅជាកម្មសិទ្ធិករ នៃដីនេះបានទេឡើយ ។

- យល់ឃើញថា ឈ្មោះ វ៉ែត វេងវ៉ែត បានថ្លែងពីឈ្មោះ លី ផង់ អ៊ី វេងវីន ស៊ូ គីមលាន និង ទុំ ញ៉ា ក្នុងរឿងព្រហ្មទណ្ឌពីបទរំលោភលើទំនុកចិត្តរួចហើយ ។ ដូច្នេះ ឈ្មោះ វ៉ែត វេងវ៉ែត អាចទារសំណង និង ព្យួនកម្ម និង ជំងឺចិត្តពីអ្នកទាំង ៤នេះបាន ។

- យល់ឃើញថា គូភាគី បានធ្វើសារណាការពារផលប្រយោជន៍របស់ខ្លួនជូនមកតុលាការកំពូល រួចហើយ ហើយដើមចោទ ចុងចម្លើយ និង មេធាវីចុងចម្លើយ ក៏បានទទួលដីកាកោះរួចហើយ ប៉ុន្តែមិនបានមកចូលរួមនាពេលសវនាការនេះទេ ដូច្នេះតុលាការកំពូល ជំនុំជំរះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាសម្រេចលេខ ១៥៥ "ឃ" ចុះថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចលើបណ្ដឹងនេះមានលក្ខណៈត្រឹមត្រូវ ទាំងទំរង់ និង អង្គច្បាប់ហើយ ។

ដ ោ យ ហ េ ត ុ ន េ ះ

វិនិច្ឆ័យសេចក្ដីចំពោះមុខមេធាវីដើមចោទ កំបាំងមុខគូក្ដី និង មេធាវីចុងចម្លើយ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្ដឹងសាទុក្ខលេខ ៣៨៥ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០១ របស់លោក វ៉ែត វេងវ៉ែត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែមិនសមស្របទៅតាមខ្លឹម នឹងអង្គច្បាប់ ។

២- តម្កល់សាលដីកាសម្រេចលេខ ១៥៥ "ឃ" ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្ដី ចំនួន ១៥.០០០រៀល ដែលលោកផាត់ ប៊ុន បានបង់ទុកនៅតុលាការកំពូល គឺ :-

- ពន្ធចុះបញ្ជីក្ដី និង ពន្ធតែម ចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជាតង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

--- --

- ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប - ១៨.០០០រៀល ដែលត្រូវអោយលោក រឹទ្ធ ចេងរ័ត សងប្រាក់ចំនួន ១៨.០០០រៀល ទេះទៅលោក ផាត់ ម៉ិន វិញ ។

បង្គាប់អោយលោក រឹទ្ធ ចេងរ័ត បង់ពន្ធសមាមាត្រតាមការកំណត់របស់ តុលាការថ្នាក់ក្រោម ។

៥- សាលដីកានេះជំនុំជម្រះដោយសវនាការជាសាធារណៈនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០០២។